**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ០៤៥៧ អបស.អឧម.សស

# សេចក្ដីសម្រេច
## ស្ដីពី
## ការទទួលស្គាល់មន្ទីរពេទ្យបង្អែកក្រឡាញ់ ជាគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលមាត្រា៥ មាត្រា៧ មាត្រា១២ មាត្រា១៧ នៃអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ និងមាត្រា៦ថ្មី នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្ដីពីការបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាល
- បានឃើញប្រកាសលេខ ២៨១ អបស.អធម/ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ស្ដីពីការកែសម្រួលកម្មវិធីសិក្សាជាតិថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក នៅតាមគ្រឹះស្ថានបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាល
- បានឃើញប្រកាសលេខ ០៧៨ អបស.អធម/ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ ស្ដីពីស្តង់ដាអប្បបរមានៃគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល

# សម្រេច

**ប្រការ១.—**

ត្រូវបានទទួលស្គាល់ **មន្ទីរពេទ្យបង្អែកក្រឡាញ់** ជាគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក ដែលមានសមត្ថភាពទទួលនិស្សិតចុះកម្មសិក្សាគ្លីនិក ចំនួន២០នាក់ ក្នុងមួយវេន។

**ប្រការ២.—**

សេចក្ដីសម្រេចស្ដីពីការទទួលស្គាល់នេះ មានសុពលភាពរយៈពេល ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា។ មន្ទីរពេទ្យបង្អែកក្រឡាញ់ ត្រូវស្នើសុំការវាយតម្លៃឡើងវិញពីក្រសួងសុខាភិបាល ដើម្បីបន្តសុពលភាពឱ្យបាន យ៉ាងតិច ២(ពីរ)ខែមុនកាលបរិច្ឆេទផុតកំណត់។

**ប្រការ៣.—**

ក្នុងករណីមន្ទីរពេទ្យមិនអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងប្រកាសលេខ ០៧៨ អបស.អធម/ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ ស្ដីពីស្តង់ដាអប្បបរមានៃគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិកសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក ក្រសួងសុខាភិបាលមានសិទ្ធដកហូតសេចក្ដីសម្រេចនេះ។

**ប្រការ៤.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.—**

អគ្គនាយកបច្ចេកទេសសុខាភិបាល ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងប្រធានមន្ទីរពេទ្យបង្អែកក្រឡាញ់ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១១កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **ឈាង រ៉ា**

**កន្លែងទទួល៖**

- ខុទ្ទកាល័យឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តសៀមរាប
- គ្រប់គ្រឹះស្ថានបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាល
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ